ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ១៤០

ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥

សាលដីកា

លេខ : ៦៦

ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៦

នាមនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | វៀល មួន | ចៅក្រម |
| ៤- លោក | ស៊ុន ឌីម | ចៅក្រម |
| ៥- លោក | សោម សិរីវឌ្ឍ | ចៅក្រម |
| ៦- លោក | ប៉ែន សារឿន | ចៅក្រម |
| ៧- លោក | យស់ សួខឿន | ចៅក្រម |
| ៨- លោក | ម៉ុង មុន្នីចរិយា | ចៅក្រម |
| ៩- លោក | យូរ ឧត្តរា | ចៅក្រម |
| អ្នកស្រី | សុជុន សុមាទីកា | ក្រឡាបញ្ជី |

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទីII ពីសាលដីកាព្រហ្មទណ្ឌលេខ ២២ "ក" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ១៤០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

ពីបទ : ចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០២ បទល្មើសដែលបញ្ញត្តិ ឱ្យផ្តន្ទាទោសមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញាឆ្នាំ១៩៩២។

១-ជនជាប់ចោទឈ្មោះ សូរ ភា ( ម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៤ឆ្នាំ សញ្ជាតិខ្មែរ កើតនៅ ភូមិតាឡី សង្កាត់ដង្កោ ខ័ណ្ឌដង្កោ ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៦E,B សង្កាត់ ផ្សារដេប៉ូ៣ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ របររកស៊ីមេផ្ទះ ។ ឪពុកឈ្មោះ អៀប សួរ

"ស" ម្ដាយឈ្មោះផេត ខុន "ស" ប្ដីឈ្មោះស៊ន សំអូន មានកូន០៧នាក់ ។ ទោសពីមុនគ្មាន ។

២-ជនជាប់ចោទឈ្មោះរត្ន័ ចាន់សុភ័ក្ត្រ ( ម្ចាស់បណ្ដឹងសាទុក្ខ) ភេទស្រី អាយុ២១ឆ្នាំ សញ្ជាតិខ្មែរ កើតនៅសង្កាត់ផ្សារថ្មី៣ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះលេខ៤៦E ផ្លូវ១១០ សង្កាត់ផ្សារដេប៉ូ៣ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ របររកស៊ីធ្វើការនៅសណ្ឋាគារ ។ ឪពុកឈ្មោះរត្ន័ សុជាន់ "រ" ម្ដាយ ឈ្មោះសូរ ភា "រ" ។ ទោសពីមុនគ្មាន ។

៣-ជនជាប់ចោទឈ្មោះរត្ន័ អង្គាបូរ ( ម្ចាស់បណ្ដឹងសាទុក្ខ) ភេទស្រី អាយុ២០ឆ្នាំ សញ្ជាតិខ្មែរ កើតនៅ សង្កាត់ផ្សារថ្មី៣ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះលេខ៤៦E, ផ្លូវ១១០ សង្កាត់ផ្សារដេប៉ូ៣ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ របររកស៊ីបុគ្គលិកសណ្ឋាគារប្រេស៊ីដង់។ ឪពុកឈ្មោះរត្ន័ សុជាន់ "រ" ម្ដាយឈ្មោះសូរ ភា "រ" ។ ទោសពីមុនគ្មាន ។

-ជនជាប់ចោទទាំង៣នាក់ មានមេធាវី លោក យុង ផានិត

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះចេង វុធីណា ( ម្ចាស់បណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៤៦E,C សង្កាត់ផ្សារដេប៉ូ៣ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។ របររកស៊ីជាសន្តិសុខមន្ទីរពេទ្យកាល់ម៉ែត ។ ឪពុកឈ្មោះចេង ថន "ស" ម្ដាយឈ្មោះ ជាត់ ខាន់ "ស" ប្រពន្ធឈ្មោះសេង សុវណ្ណា មានកូន០២នាក់ ។

- មេធាវី លោក លី ស៊ាងហួរ

-តាមពាក្យបណ្ដឹងជនរងគ្រោះឈ្មោះចេង វុធីណា ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០២វេលាម៉ោង ១០"៣០"'យប់ ក្រុមគ្រួសាររបស់ជនរងគ្រោះ និងជនរងគ្រោះបាននាំគ្នាដេកលង់លក់ទាំងអស់គ្នា ហើយនៅក្នុងផ្ទះមានមនុស្សដេកចំនួន០៥នាក់ ប្រុស២ ហើយការដេកនោះ គឺ២នាក់ប្ដីប្រពន្ធបានដេកនៅក្នុងបន្ទប់ដោយមិនបានបិទទ្វារបន្ទប់ឡើយ ចំណែកអ្នកនៅខាងក្រៅមានមនុស្សដេក៣នាក់ គឺម្ដាយក្មេកជនរងគ្រោះ និងកូន២នាក់របស់ជនរងគ្រោះ ដោយពុំមានបិទទ្វារខាងមុខដែរ ហើយពុំដឹងថាបាត់របស់តាំងពីម៉ោងប៉ុន្មានដែរ លុះព្រឹកជនរងគ្រោះភ្ញាក់ពីដំណេក ក៏ក្រោកឡើងរកមើលទូរស័ព្ទ ស្រាប់តែបាត់ទូរស័ព្ទ ពេលនោះជនរងគ្រោះត្រួតពិនិត្យមើលទៀត ស្រាប់តែឃើញមានបាត់ខ្សែក នាឡិកា លុយចិញ្ចៀន និងឯកសារលិខិតស្នាមផ្សេងៗទៀតមួយចំនួនធំ សង្ស័យ ជនរងគ្រោះក៏ដើរទៅមើលជុំវិញផ្ទះ ក៏ស្រាប់តែឃើញមានស្នាមជាន់ជើងចេញពីផ្ទះឈ្មោះភា ផ្ទះលេខ៤៦E,B ផ្លូវ១១០ ក្រុម៥ សង្កាត់ផ្សារ-ដេប៉ូ៣ ។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការក្រុងភ្នំពេញសំរេចៈ ចោទប្រកាន់លើឈ្មោះ សូរ ភា ភេទស្រី អាយុ៤៤ឆ្នាំ, ឈ្មោះ រត្ន័ អង្គាបូរ ភេទស្រី អាយុ២០ឆ្នាំ និងឈ្មោះ រត្ន័ ចាន់សុភ័ក្ត្រ ភេទស្រី អាយុ ២២ឆ្នាំ ពីបទ ចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០២ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៦៧"ដ" ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេច :

១-ផ្តន្ទាទោសឈ្មោះ សូរ ភា ភេទស្រី អាយុ៤៤ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន៨ខែ តែទោសនេះ ត្រូវព្យួរក្នុងរយៈពេលសាកល្បង០៥ឆ្នាំ ពីបទចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០២ តាមបញ្ញត្តិមាត្រា៤៣ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ផ្តន្ទាទោសឈ្មោះរត្ន័ អង្គាបូរ ភេទស្រី អាយុ២០ឆ្នាំ និងឈ្មោះរត្ន័ ចាន់សុភ័ក្ត្រ ភេទស្រី អាយុ២២ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួនម្នាក់១៨ខែ តែទោសនេះត្រូវព្យួរក្នុងរយៈពេលសាកល្បង ០៥ឆ្នាំ ពីបទចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០២ តាមបញ្ញត្តិមាត្រា៤៣ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-បង្គាប់អោយឈ្មោះសូរ ភា ,រត្ន័ អង្គាបូរ , រត្ន័ ចាន់សុភ័ក្ត្រ រួមគ្នាសងថ្លៃទ្រព្យសម្បត្តិដែលបាត់បង់ចំនួន២.០០០ដុល្លា និង ជម្ងឺចិត្ត៥០០ ដុល្លា សំណូមពរលើសពីនេះ បដិសេធចោលអោយទៅឈ្មោះចេង វុធីរិណា ជាជនរងគ្រោះ ករណីរឹងទទឹងមិនព្រមសងត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង និងដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ ។

៤-កាបូបស្ពាយ(ស្រី) ពណ៌ខ្មៅ០១ ត្រូវប្រគល់អោយម្ចាស់ដើមវិញ ។

៥-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងរយៈពេល២ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះ សូរ ភា . រត្ន័ ចាន់សុភ័ក្ត្រ និង ឈ្មោះ រត្ន័ អង្គាបូរ ដែលប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៦៧"ដ" ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចនៃសាលក្រមទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : សុំរក្សាការចោទប្រកាន់ដដែល តែសុំអោយពិចារណាលើសំណងរដ្ឋប្បវេណី ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៤២"ដ" ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះសូរ ភា ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០២ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះរត្ន័ ចាន់សុភ័ក្ត្រ និង រត្ន័ អង្គាបូរ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៦៧"ដ" ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញទុកជាបានការ លើកលែងតែចំណុចទី២នៃសាលក្រមត្រូវបដិសេធចោលដោយសំរេច

អោយឈ្មោះ រត្ន័ ចាន់សុភ័ក្ត្រ និង រត្ន័ អង្គាបូរ រួចផុតពីការចោទប្រកាន់ និងកែប្រែចំណុចទី៣ នៃសាលក្រមដែលបង្គាប់អោយឈ្មោះសួរ ភា សងថ្លៃទ្រព្យសម្បត្តិដែលបាត់បង់ចំនួន១.០០០$ ( មួយពាន់ដុល្លាអេមេរិក) វិញ ចំណុចផ្សេងទៀត រក្សាទុកដដែល ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និង មេធាវីការពារជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៨៨ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះសួរ ភា ប្តឹងមិនសុខចិត្ត នឹងសាលដីកាព្រហ្មទណ្ឌលេខ៨៤២"ជ" ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី៣នៃសាលដីកា ដែលដាក់ទោសនាងខ្ញុំ០៨ខែ ព្យួរ និងបង្គាប់អោយនាងខ្ញុំសង ១០០០ដុល្លា ។ និងបណ្តឹងសាទុក្ខលេខ១០៣ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះចេង វុធីណា ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៨៤២"ជ" ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី៣ នៃសាលដីកាទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា :

+មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះសួរ ភា ភេទស្រី អាយុ៤៤ឆ្នាំ ឈ្មោះរត្ន័ អង្គាបូរ ភេទស្រី អាយុ២០ឆ្នាំ, ឈ្មោះរត្ន័ ចាន់សុភ័ក្ត្រ ភេទស្រី អាយុ២១ឆ្នាំ ពីបទចោរកម្មប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០២ បទល្មើសដែលបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

+បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៨៤២"ជ" ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ចោលជាអាសារបង់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២១ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៤របស់តុលាការកំពូល ដែលមានខ្លឹមសារ នៃសេចក្តីសំរេច :

១-ទទួលបណ្តឹងសាទុក្ខលេខ៨៨ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះសួរ ភា និង បណ្តឹងសាទុក្ខលេខ១០៣ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៣ របស់លោកចេង វុធីណា ទុកជាត្រឹមត្រូវតាមទំរង់ នឹងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ៨៤២"ជ" ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៨៥ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-សាលដីកានេះជំនុំជំរះ នាសវនាការជាសាធារណៈនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ និង ប្រកាសនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៤ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : សុំតុលាការសំរេចតាមច្បាប់ចុះ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២២"ក" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេច :

១-ទទួលរឿងក្តីព្រហ្មទណ្ឌលេខ៩៤១ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ជំនុំជំរះឡើងវិញ តាមអំណាចសាលដីកាលេខ២១ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

២-ផ្តន្ទាទោសឈ្មោះសួរ ភា ភេទស្រី អាយុ៤៤ឆ្នាំ ជាតិខ្មែរ, រត្ន័ អង្គាបូរ ភេទស្រី អាយុ២០ឆ្នាំ ជាតិខ្មែរ . រត្ន័ ចាន់សុភ័ក្រ្ត ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ម្នាក់១៨ខែ (ប្រាំបីខែ) តែទោសនេះត្រូវព្យួរក្នុងរយៈពេលសាកល្បងចំនួន០៥ឆ្នាំ ពីបទ "ចោរកម្ម" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០២ តាមបញ្ញត្តិមាត្រា៤៣ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៣-បង្គាប់ឱ្យឈ្មោះសួរ ភា . រត្ន័ អង្គាបូរ . រត្ន័ ច័ន្ទសុភ័ក្រ្ត រួមគ្នាសងថ្លៃទ្រព្យសម្បត្តិដែលបាត់បង់១.៥០០US$ (មួយពាន់ប្រាំរយដុល្លាអាមេរិក) និងជំងឺចិត្ត ៥០០$ (ប្រាំរយដុល្លាអាមេរិក) សំណូមពរលើសពីនេះបដិសេធចោល ។

៤-សាលដីកានេះជំនុំជំរះសាធារណៈនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៥ចំពោះមុខមេធាវីជនជាប់ចោទ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី . ដើមបណ្តឹងរដ្ឋប្បវេណី . ជនជាប់ចោទឈ្មោះសួរ ភា ជនជាប់ចោទឈ្មោះរត្ន័ អង្គាបូរ កំបាំងមុខជនជាប់ចោទឈ្មោះរត្ន័ ច័ន្ទសុភ័ក្រ្ត និង ប្រកាសជាសាធារណៈនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៥ ចំពោះមុខជនជាប់ចោទឈ្មោះសួរ ភា .ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខមេធាវីជនជាប់ចោទ . មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទឈ្មោះរត្ន័ អង្គាបូរ . ជនជាប់ចោទឈ្មោះរត្ន័ ច័ន្ទសុភ័ក្រ្ត បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ១០៦ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះសួរ ភា . រត្ន័ ចាន់សុភ័ក្រ្ត . រត្ន័ អង្គាបូរ ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ២២"ក" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល និងបណ្តឹងសាទុក្ខលើកទី២លេខ១២៤ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៥ របស់ឈ្មោះ ចេង វុធីរ៉ាណា ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ២២"ក" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចផ្តន្ទាទោស និង សំណងដូចតុលាការក្រុងភ្នំពេញ ។

-បានឃើញសារណាការពារ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ និង សារណាតប ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៦ របស់ឈ្មោះសួរ ភា . រត្ន័ អង្គាបូរ . រត្ន័ ចាន់សុភ័ក្រ្ត ។

-បានឃើញសារណាការពារ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥ និង សារណាតប ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ឈ្មោះចេង វុធរីណា ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : ពុំទាន់មានភស្តុតាងដាក់បន្ទុកលើជនត្រូវចោទឈ្មោះសួរ ភា . រត្ន័ ចាន់សុភ័ក្រ្ត . រត្ន័ អង្គាបូរ ពីបទចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលឡើយ ។ ហេតុនេះសូមឯកឧត្តមប្រធាន និង ក្រុមប្រឹក្សាជំនុំជំរះពិនិត្យនិងសំរេច ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ សួរ ភា នាពេលសវនាការថា: ការព្យាយាមទំលាក់កំហុសមកលើក្រុមគ្រួសារនាងខ្ញុំ គឺជាការចោទប្រកាន់ គ្មានភស្តុតាង គ្មានសាក្សី ។ គាត់បានសុំទិញដីបូលផ្ទះរបស់នាងខ្ញុំ តែនាងខ្ញុំពុំព្រមលក់ គាត់មានគំនុំគំគួនខ្ញុំ។ នាងខ្ញុំមិនបានដឹងអ្វីទេ ពេលព្រឹកឡើងគាត់មកសួរខ្ញុំ ពេលគាត់បាត់របស់ ក្នុងគ្រួសារនាងខ្ញុំមានកូនស្រីពីរនាក់ ក្មួយម្នាក់ និងកូនតូច១ ។ ផ្ទះគាត់មានរបងដាក់ចំរឹងដែក២៣ ទ្វារអាចចូលពីក្រោយបាន វេរ៉ង់ដា ក៏មានចំរឹងដែកដែរ គាត់ចោទថា នាងខ្ញុំចូលលួចទ្រព្យសម្បត្តិ ផ្ទះគាត់បិទទ្វាររហូត ខ្ញុំមិនដែលចេញចូលផ្ទះគាត់ទេ។ នាងខ្ញុំមិនបានលួចយកទ្រព្យសម្បត្តិរបស់គេទេ តុលាការក្រុងបានចេញបញ្ជាយកនាងខ្ញុំទៅដាក់គុកមួយខែទៀត ដោយអយុត្តិធម៌ជាទីបំផុត ។

+ តើផ្ទះរបស់អ្នកអាចឆ្លងចូលផ្ទះរបស់គេបានទេ ?

-ឆ្លងមិនបានទេ លោកតុលាការ

+តើផ្ទះអ្នកមានសមាជិកពេញវ័យប៉ុន្មាននាក់ ?

-ផ្ទះនាងខ្ញុំមានអ្នកពេញវ័យគ្នាបួននាក់ សុទ្ធតែស្រី១ និងកូនតូច១ ។

-បញ្ហាយកកាបូបខ្មៅមកផ្តុងចោល និងបញ្ហាមានស្នាមដានជើងចូល ប៉ូលីសចុះមកត្រួតពិនិត្យ និងស៊ើបអង្កេត ជាលទ្ធផលប៉ូលីសពុំបានរកឃើញថា ជារបស់អ្នកណាទេ ។

<u>សំណូមពរ</u> :សូមឱ្យលោកតុលាការ មេត្តាជួយរកយុត្តិធម៌ឱ្យនាងខ្ញុំផង ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ រត្ន័ ចាន់សុភ័ក្រ្ត ហៅ ស្រី ម៉ុច នាពេលសវនាការថា: នាងខ្ញុំមិនបានដឹងអ្វីទេ ព្រោះខ្ញុំទៅធ្វើការបាត់ហើយ "ធ្វើការនៅលីហ្វូ" ។

+តើយប់ថ្ងៃកើតហេតុអ្នកនៅឯណា ?

-នាងខ្ញុំនៅផ្ទះ ភ្លឺឡើងក៏ទៅធ្វើការតែម្តង ហើយខ្ញុំមកពីធ្វើការវិញ នៅម៉ោង៩យប់ ។

+តើចំរឹងដែកគាត់បានដាក់យូរហើយនៅ?

-ផ្ទះគាត់បានដាក់ចំរឹងដែកយូរមកហើយ ។

សំណូមពរៈសូមឱ្យលោកតុលាការ មេត្តាជួយរកយុត្តិធម៌ឱ្យនាងខ្ញុំផង ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះចេង វុធវីណា នាពេលសវនាការថាៈ

+ ពេលបាត់របស់ គឺជាខែចូលឆ្នាំ អាកាសធាតុក្តៅ ពេលគេងយប់ខ្ញុំបាទ និងក្រុមគ្រួសារពុំបានបិទទ្វារបន្ទប់ និងទ្វារផ្ទះខាងមុខទេ ។

+ ចំរឹងដែកខ្ញុំបាទធ្វើនៅក្រោយពេលកើតហេតុ ។ ពីមុនមកមានឈ្មោះ សួរ ភា បានចេញចូលផ្ទះរបស់ខ្ញុំ មើលទូរទស្សន៍ជាធម្មតា ។

+ពេលដឹងថា បាត់របស់ ខ្ញុំបាទបាននិយាយ នៅព្រឹកថ្ងៃកើតហេតុ នឹងតែម្តងជាមួយ សួរ ភា ជាម្តាយថា បើមិនហ៊ានយកមកឱ្យខ្ញុំផ្ទាល់ទេ ដាក់ផ្លុងចោលកន្លែងណាក៏បាន មួយថ្ងៃក្រោយមក ទើបឃើញកាបូបខ្មៅយកមកផ្លុងនៅក្រោមកៅអីរានហាលមុខផ្ទះ ។ ប្អូនប្រុសជីដូនមួយខ្ញុំបាទនៅអាភាកោងបានឃើញកាបូបនេះ ហើយទូរស័ព្ទ ហៅខ្ញុំពីកន្លែងធ្វើការមក ។ កាបូបដែលឃើញមានចំងាយ ១.៥ម ពីរានហាលខាងមុខ ខ្ញុំមិនអស់ចិត្តក៏បានទូរស័ព្ទ ហៅប៉ូលីសមកធ្វើការត្រួតពិនិត្យទាំងអស់គ្នា ។

+នៅរវាំងដា មានប្រវែងហែល៣ម ខ្ញុំដាំគល់ស៊្មីកគ្រែវាបាក់ខ្ទេចទាំងអស់ ហើយឃើញមានស្នាមដានជើងចេញចូលទាំងផ្ទះគេ និងផ្ទះរបស់ខ្ញុំបាទ ។ ខ្ញុំបានថតស្នាមចេញចូលទាំងនោះ នៅនឹងផ្ទះខ្ញុំ ខ្ញុំមិនអាចថតស្នាមដានជើងទាំងផ្ទះគេទេ ព្រោះពេលនោះមានការថ្នាំងថ្នាក់រវាងគ្នាហើយ ។

+ខ្ញុំបាទមិនបានធ្វើការវាស់វែងដានជើងនោះទេ តែខ្ញុំជឿជាក់ថា មានម្នាក់ និងអ្នកឃុបឃិតមានគ្នា២នាក់ ចូលលួចយកទ្រព្យសម្បត្តិផ្ទះខ្ញុំ ជាក់ស្តែងមានបាក់មែកឈើស្រស់១ និងឃើញកាបូបខ្មៅយកមកផ្លុង ក្រោយពីខ្ញុំបាទបាននិយាយជាមួយ សួរ ភា រួច ខ្ញុំក៏ដាក់ពាក្យប្តឹងរហូត មានរយៈពេល៤ឆ្នាំហើយ ។

+ក្នុងកាបូបឃើញមានលុយជាង១០ម៉ឺនរៀល និង លុយដុល្លា៣០$ កូនសោឡាន ហើយលុយ១ដុល្លា មានចារ ក៏ឃើញដែរ គឺមានទាំងអស់ ។

+ ពេលបានកាបូបវិញ មានឱ្យប៉ូលីសធ្វើការអង្កេតទេ?

-ខ្ញុំបាទបានឱ្យប៉ូលីសធ្វើការអង្កេតទាំងអស់

+កាបូបត្រូវតែមានធ្វើកោសលវិច្ច័យ

+ស្នាមដានជើងត្រូវតែមានធ្វើការវាស់វែង

សំណូមពរៈ សូមតំកល់សាលក្រមព្រហ្មទណ្ឌលេខ៦៧"ដ" ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក យុង ជាទិត មេធាវីការពារឱ្យជនជាប់ចោទទាំង៣នាក់ នាពេលសវនាការថាៈ ជនរងគ្រោះចោទមកលើកូនក្តីខ្ញុំបាទ សុទ្ធតែជាការសង្ស័យទាំងអស់ ។ នៅតុលាការក្រុងសំរេច គឺគ្មានភស្តុតាង គ្មានមូលដ្ឋានគ្រប់គ្រាន់ជាសំអាងទេ ។ សាលាឧទ្ធរណ៍សំរេច ពុំមានហេតុផល

ណាមួយបញ្ជាក់ថា កូនក្តីខ្ញុំបាទជាអ្នកចូលលួចទ្រព្យសម្បត្តិគេទេ ។ រាល់ការចោទប្រកាន់ សុទ្ធតែជាវិមតិសង្ស័យទាំងអស់ទាំងតុលាការក្រុង ទាំងសមត្ថកិច្ច ។ ផ្ទះនោះអាចឡើងពីមុខ ពីចំហៀងក៏បានមិនដឹងអ្នកណាមួយផ្សេងទៀត ក្រៅពីកូនក្តីខ្ញុំបាទចូលលួចក៏អាចថាបាន ក្មួយរបស់គាត់ ក៏អាចយកទ្រព្យសម្បត្តិរបស់គាត់បានដែរ ។

សូមក្រុមប្រឹក្សាជំនុំជំរះ ពិនិត្យត្រង់មាត្រា២៦ ចំណុច១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល បើសិនជាមានវិមតិសង្ស័យ សូមតុលាការកំពូលសំរេចធ្វើការលើកលែងចោទប្រកាន់ដល់កូនក្តីខ្ញុំបាទ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកលី ស៊ាងហួរ មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី នាពេលសវនាការថា: សូមតុលាការ ពិនិត្យលើផ្ទះល្វែងជាប់គ្នារវាងកូនក្តីខ្ញុំបាទ និង ផ្ទះ សួរ ភា ។ ទាំងផ្ទះជនរងគ្រោះ ទាំងផ្ទះជនជាប់ចោទ ពិនិត្យឃើញថា ពិតជាមានដានជើងធំ១ និងមានបាក់ដើមស្លឹកគ្រៃ និងបាក់មែកឈើស្រស់១ពិតប្រាកដ ។ មានយកកាបូបមកដូរឱ្យវិញ ក្រោយពេលបាននិយាយជាមួយឈ្មោះសួរ ភា ។

សំណូមពរ : សូមតម្កល់សាលក្រមព្រហ្មទណ្ឌលេខ៦៧"ដ" ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០២ របស់តុលាការក្រុង ទុកជាបានការពេញទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: ពុំទាន់មានភស្តុតាងដោះបន្ទុក ឬ ដាក់បន្ទុក និង ដើម្បីប្រយោជន៍ដល់ជនត្រូវចោទ ជនរងគ្រោះ និង ដើម្បីជាប្រយោជន៍ច្បាប់ ដូចនេះ សូមឯកឧត្តមប្រធាន និងក្រុមប្រឹក្សាជំនុំជំរះ គួរចាត់របៀប ដើម្បីធ្វើការស៊ើបអង្កេតបន្ថែម ឬសុំសំរេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ សួរ ភា. រត្ន័ ចាន់សុភ័ក្រ្ត ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១០៦ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះ សួរ ភា រត្ន័ ចាន់សុភ័ក្រ្ត. រត្ន័ អង្គាបូរ និងបណ្តឹងសាទុក្ខលេខ១២៤ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៥ របស់ឈ្មោះ ចេង វុធរីណា ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចជាលើកទី២ ដោយចោទប្រកាន់ និងផ្តន្ទាទោសលើឈ្មោះ សួរ ភា .រត្ន័ ចាន់សុភ័ក្រ្ត និង រត្ន័.អង្គាបូរ ដោយសំអាងថា ការបង្ហាញហេតុផលរបស់ដើមបណ្តឹងរដ្ឋប្បវេណី តាមស្ថានភាពនៃទីតាំងលំនៅដ្ឋាននៅជាប់គ្នា ដូចនេះ ក្រៅពីគ្រួសារជនជាប់ចោទ គឺពុំមាននរណាចេញចូលបានទេ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា គ្រាន់តែលំនៅដ្ឋាននៅជាប់គ្នា ពុំមែនជាភស្តុតាងតែមួយគត់សំរាប់ដាក់បន្ទុកទេ ហើយម្យ៉ាងទៀតច្បាប់ពុំអនុញ្ញាតិឱ្យចោទប្រកាន់ និងផ្តន្ទាទោស ចំពោះជនណាម្នាក់ ដោយពុំមានភស្តុតាងច្បាស់លាស់ទេ ។

-យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោមបានសំរេចចោទប្រកាន់ និងផ្តន្ទាទោសមនុស្សដល់ទៅ៣នាក់នោះ ដែលតាមអង្គហេតុ អ្នកដែលចូលលួចមានតែម្នាក់ទេ ហើយបើតុលាការសំរេចចោទប្រកាន់មនុស្ស៣នាក់នោះ ក៏គប្បីតុលាការកែប្រែបទចោទ ពីបទចោរកម្មទៅជាបទប្លន់ដែរ ។

-យល់ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាព លើជនជាប់ចោទទាំង៣នាក់នេះទេ ។

-យល់ឃើញថា ការដែលដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចមេធាវីរបស់ឈ្មោះនេះដែរ ដែលលើកឡើងនាសវនាការនេះ គ្រាន់តែជាការសន្និដ្ឋាន ដោយស្មានប៉ុណ្ណោះ ដែលពុំមានជាភស្តុតាងជាក់លាក់ដែលអាចអោយតុលាការពិចារណាបានទេ ។

-យល់ឃើញថា ជនជាប់ចោទឈ្មោះ រត្ន័ អង្គាបូរ ពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះ រឿងនេះ កំបាំងមុខឈ្មោះនេះ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២២"ក" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះ សួរ ភា, រត្ន័ ចាន់សុភ័ក្រ្ត និងដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខ រត្ន័ អង្គាបូរ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ ១០៦ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះ សួរ ភា . រត្ន័ ចាន់សុភ័ក្រ្ត និង រត្ន័ អង្គាបូរ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

-ទទួលបណ្តឹងសាទុក្ខលេខ១២៤ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៥ របស់ឈ្មោះចេង វុធរីណា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ២២"ក" ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ ២០០៥ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-សំរេចឱ្យឈ្មោះ សួរ ភា . រត្ន័ ចាន់សុភ័ក្រ្ត និង រត្ន័អង្គាបូរ រួចផុតពីការចោទប្រកាន់ក្នុងបទចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០២ ចាប់ពីថ្ងៃប្រកាសសាលដីកានេះតទៅ ។

៤-សាលដីកានេះ ជំនុំជំរះ និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០០៦ ។